# អង្គការតំណក់ទឹក (ត.ទ)

**Damnok Toek ( Goutte d’Eau) (DT)**

ជួយកុមារងាយរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ

# គោលនយោបាយការពារកុមារ


| អ្នកលឿង | ប៉ោយប៉ែត | ភ្នំពេញ |
|---|---|---|
| ភូមិព្រែកខ្សាយឃុំព្រែកខ្សាយក | សមាគមចន្ទគិរី | ផ្ទះលេខ ១៩៩ ផ្លូវសំរោងអណ្តែត |
| ស្រុកពាមរក៍ ខេត្តព្រៃវែង | សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត | ភូមិច្រេស សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ |
| ខេត្តបន្ទាយមានជ័យ | | រាជធានីភ្នំពេញ |

រាជធានីភ្នំពេញ

ទូរស័ព្ទ៖ (+៨៨៥) ៨៣ ៧៥០ ១៥៨ ទូរស័ព្ទ៖ (+៨៥៥) ០១៧ ២៨១ ៥២៨ ទូរស័ព្ទ៖ (+៨៥៥) ០១២ ៨៥១ ១៣០

អ៊ីមែល៖neakloeung@damnoktoek.org អ៊ីមែល៖ poipet@damnoktoek.org អ៊ីមែល៖ phnompenh@damnoktoek.org


វែបសាយត៍៖

## មាតិកា

## គោលនយោបាយការពារកុមារ


✦ ហេតុអ្វីត្រូវមានគោលនយោបាយការពារកុមារ……………………………………………………..3

✦ តើយើងជាអ្នកណា…………………………………………………………………………….4

✦ ទស្សនវិស័យ និងបេសកកម្មរបស់យើង…………………………………………….5

- ទស្សនវិស័យរបស់យើង………………………………………………………………..5
- បេសកកម្មរបស់យើង……………………………………………………………...5
- គុណតម្លៃរបស់យើង………………………………………………………………6

✦ សេចក្តីថ្លែងអំពីការប្តេជ្ញាចិត្ត…………………………………………………………………...6

✦ អង្គការតំណក់ទឹកហាមឃាត់គ្រប់ទម្រង់នៃការរំលោភបំពានលើកុមារ………………………6

✦ ក្រមនៃការអនុវត្ត និងអាកប្បរិយា…………………………………………………7

✦ ការជ្រើសរើស និងការសម្រាំង………………………………………………………………….10

✦ការទំនាក់ទំនងអំពីការការពារនិងការរំលោភបំពានលើកុមារ ………………………………..11

✦ការឆ្លើយតបទៅនឹងការចោទប្រកាន់ចំពោះការរំលោភបំពានលើកុមារ……………………….12

✦ ឧបសម្ព័ន្ធ ១……………………………………………………………………………………..14

✦ ឧបសម្ព័ន្ធ ២ ការធ្វើទស្សនកិច្ចគម្រោងអង្គការតំណក់ទឹក……………………………………19

✦ ឧបសម្ព័ន្ធ ៣ សេចក្តីណែនាំសម្រាប់អ្នកសារព័ត៌មាន………………………………………......20

✦ ឧបសម្ព័ន្ធ ៤ ការស្ម័គ្រចិត្តនៅតំណក់ទឹកកម្ពុជា…………………………………...........24

# តំណាក់ទឹក(តទ)

Damnok Toek ( Goutte d’Eau) (DT)

**ជួយកុមារងាយរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ**

# *គោលនយោបាយការពារកុមារ*

## *ហេតុអ្វីត្រូវមានគោលនយោបាយការពារកុមារ*

- កុមារគ្រប់រូបមានសិទ្ធិទទួលបានការការពារពីទម្រង់ណាមួយ នៃការរំលោភរំលោភបំពាន អំពើហិង្សា ការរងរបួស ការព្រងើយកន្តើយ ការប្រព្រឹត្តមិនត្រឹមត្រូវ ឬការកេងប្រវ័ញ្ច។ តំណាក់ទឹក (DT) ធ្វើការដើម្បីបង្កើតបរិយាកាសដែលមានសុវត្ថិភាពមួយសម្រាប់កុមារដែលជាអ្នកទទួលបានផលប្រយោជន៍ពីគម្រោងផ្សេងៗរបស់យើង។
- កុមារ និងយុវជនត្រូវការការការពារ និងការការពារសុវត្ថិភាព។ ដំបូងបំផុត ពួកគេត្រូវការការការពារពីផលប៉ះពាល់នៃភាពក្រីក្រ ការបាត់បង់ឱកាស ការផាត់ចេញ និងអំពើហិង្សា។ ក្រៅពីបញ្ហាសេដ្ឋកិច្ច សង្គម និងនយោបាយទាំងនេះ កុមារនីមួយៗអាចប្រឈមនឹងគ្រោះថ្នាក់នៃទម្រង់ដទៃទៀតនៃការរំលោភរំលោភបំពានពីមនុស្សពេញវ័យ ឬកុមារដទៃទៀត។ នៅក្នុងគោលនយោបាយនេះ DT បានយកចិត្តទុកដាក់ជាពិសេសចំពោះការការពារកុមារដែលមានទំនាក់ទំនងជាមួយបុគ្គលិក ឬតំណាងរបស់ DT។
- គោលនយោបាយនេះថែងអំពីគុណតម្លៃរួម គោលការណ៍ និងជំនឿរបស់ DT ព្រមទាំងរៀបរាប់អំពីជំហាននានាដែលត្រូវអនុវត្តដើម្បីសម្រេចការប្តេជ្ញាចិត្តរបស់យើងក្នុងការការពារកុមារ។
- គោលនយោបាយនេះត្រូវបានឯកភាព និងអនុម័តដោយក្រុមប្រឹក្សាភិបាលរបស់ DT។ វាអនុវត្តចំពោះបុគ្គលិកទាំងអស់ ទាំងបុគ្គលិកក្នុងស្រុក និងបុគ្គលិកបរទេស អ្នកស្ម័គ្រចិត្ត និងភ្ញៀវនៅក្នុងគម្រោងរបស់តំណាក់ទឹក។
- វាជាការសំខាន់ណាស់ ដែលបុគ្គលិក អ្នកស្ម័គ្រចិត្ត ដៃគូ អង្គការអន្តរជាតិ អ្នកទទួលផល ម្ចាស់ជំនួយទាំងអស់ និងសាធារណជនទូទៅ មានការយល់ដឹងអំពីសារដ៏សំខាន់របស់គោលនយោបាយនេះ និងភារកិច្ច/ទំនួលខុសត្រូវដែលគោលនយោបាយនេះកំណត់ចំពោះពួកគេ។
- គោលនយោបាយនេះមានជាភាសាអង់គ្លេសផងដែរ។

- គោលនយោបាយនេះត្រូវបានពិនិត្យមើលឡើងវិញ យ៉ាងតិចម្តងរៀងរាល់បីឆ្នាំ ឬនៅពេលចាំបាច់។

គោលនយោបាយការពារកុមារនេះត្រូវបានបង្កើតឡើងដោយគណៈកម្មាធិការប្រតិបត្តិរបស់ DT និងត្រូវបានឯកភាពដោយក្រុមប្រឹក្សាភិបាល នៅ ..............................................

## *តើយើងជាអ្នកណា*

តំណក់ទឹកប្រទេសស្វីស បានចាប់ផ្តើមដំណើរការការងារនៅក្នុងប្រទេសកម្ពុជា នៅខែមករា ឆ្នាំ១៩៩៧ ក្រោមអនុស្សរណៈនៃការយោគយល់ (MoU) ជាមួយក្រសួងសង្គមកិច្ច បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវជន (MOSVY)។ អង្គការនេះបានជួយសាងសង់មជ្ឈមណ្ឌលមួយសម្រាប់កុមារងាយរងគ្រោះនៅអ្នកលឿង ខេត្តព្រៃវែង។ មជ្ឈមណ្ឌលនេះត្រូវបានធ្វើឲ្យមានលក្ខណៈក្នុងស្រុក និងកំពុងដំណើរការដោយឯករាជ្យជា NGO ក្នុងស្រុកមួយដែលបានចុះបញ្ជីជាមួយក្រសួងមហាផ្ទៃ ចាប់តាំងពីឆ្នាំ២០០១។

នៅខែមករា ឆ្នាំ១៩៩៩ ក្រោយពីមានការស្នើសុំដោយ MOSVY តំណក់ទឹកបានអនុវត្តកម្មវិធីមួយនៅក្រុងប៉ោយប៉ែត ដែលជាក្រុងដ៏សំខាន់មួយនៅជាប់ព្រំដែនរវាងប្រទេសកម្ពុជា និងប្រទេសថៃ ដែលមានបំណងស្តារនីតិសម្បទាដល់កុមារប្រើគ្រឿងញៀន និងធ្វើសមាហរណកម្មជនដែលធ្លាប់រងគ្រោះដោយសារអំពើជួញដូរ។ នៅក្នុងឆ្នាំ២០០៣ គម្រោងនេះក៏ត្រូវបានចុះបញ្ជីជា NGO កម្ពុជាក្នុងស្រុកនៅក្រសួងមហាផ្ទៃផងដែរ។

នៅខែសីហា ឆ្នាំ២០០៣ តំណក់ទឹក (ហ្គូតដូ) អ្នកលឿង បានបង្កើតទីជម្រកមួយនៅក្នុងទីក្រុងភ្នំពេញសម្រាប់កុមារពិការរាងកាយ និង/ឬបញ្ញារហូតដល់ ៣០ នាក់ និងមនុស្សវ័យជំទង់ដែលមកពីបណ្តាខេត្ត ដើម្បីមកបន្តការសិក្សារបស់ពួកគេ ឬរកការងារធ្វើនៅក្នុងទីក្រុងភ្នំពេញ។ ភាគច្រើននៃកុមារទាំងនេះ គឺត្រូវបានបញ្ជូនមកពីមជ្ឈមណ្ឌលតំណក់ទឹកក្រុងប៉ោយប៉ែត និងអ្នកលឿង ក៏ដូចជា មកពីអង្គការដទៃទៀតផងដែរ។ ចាប់តាំងពីពេលបង្កើតឡើងមក តំណក់ទឹកជនពិការភ្នំពេញបានក្លាយជាផ្នែកមួយនៃតំណក់ទឹក (ហ្គូតដូ) អ្នកលឿង។

នៅ XXX ឆ្នាំ២០១២គម្រោងអង្គការតំណក់ទឹកប៉ោយប៉ែតនិងអង្គការតំណក់ទឹកអ្នកលឿង បានរួមបញ្ចូលគ្នាជា NGO ក្នុងស្រុកមួយគឺអង្គការតំណក់ទឹក Damnok Toek(Goutte d'Eau) (DT)។ អង្គការតំណក់ទឹកត្រូវបានបង្កើតឡើងដើម្បីជួយដល់កុមារងាយរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ។ គោលដៅចម្បងក្នុងការបង្កើតឡើងនេះ គឺមានដូចខាងក្រោម៖

**ការទប់ស្កាត់**

ការរំលោភរំលោភបំពានលើកុមារ ការប្រើប្រាស់គ្រឿងញៀន និងការជួញដូរកុមារ (ការជួញដូរក្នុងប្រទេស និងឆ្លងព្រំដែន)

**ការស្តារនីតិសម្បទា**

អ្នកប្រើប្រាស់គ្រឿងញៀនមិនទាន់គ្រប់អាយុ និងកុមារដែលទទួលរងការប៉ះទង្គិចផ្លូវចិត្ត

**ការធ្វើសមាហរណកម្ម**

កុមារដែលត្រូវបានព្រងើយកន្តើយ និងកុមារអនាថាទៅក្នុងសង្គមខ្មែរ តាមរយៈការអប់រំក្រៅផ្លូវការ (ការអប់រំក្រៅប្រព័ន្ធ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ) និងការអប់រំក្នុងប្រព័ន្ធ (សាលារដ្ឋ)

**ការធ្វើសមាហរណកម្មឡើងវិញ**

កុមារដែលត្រូវបានជួញដូរ និងកុមាររត់គេចខ្លួនទៅក្នុងវប្បធម៌របស់ពួកគេ ភូមិរបស់ពួកគេ និងប្រសិនបើអាច ទៅក្នុងគ្រួសាររបស់ពួកគេ។

## *ទស្សនវិស័យ និងបេសកកម្មរបស់យើង*

**ទស្សនវិស័យរបស់យើង** ចង់ឃើញកុមារងាយរងគ្រោះនៅក្នុងប្រទេសកម្ពុជា (រួមមានជាអាទិ៍ជនរងគ្រោះដោយសារអំពើជួញដូរ កុមារធ្វើការតាមចិញ្ចើមថ្នល់/កុមាររស់នៅតាមចិញ្ចើមថ្នល់ និងកុមារដែលរងគ្រោះដោយសារការកេងប្រវ័ញ្ច ឬការរំលោភរំលោភបំពានគ្រប់ប្រភេទ) មានសមត្ថភាព និងឱកាសស្មើៗគ្នាក្នុងការទទួលបានសិទ្ធិរបស់ពួកគេ និងលទ្ធភាពទទួលបានតម្រូវការជាមូលដ្ឋាន ដែលមានចែងនៅក្នុងអនុសញ្ញាស្តីអំពីសិទ្ធិកុមារ។

**បេសកកម្មរបស់យើង** មានបំណងធ្វើការជាមួយកុមារដែលងាយរងគ្រោះ និងបាត់បង់ឱកាសបំផុតនៅក្នុងប្រទេសកម្ពុជា។ ដោយមានការគាំទ្រពីសហគមន៍នានា តំណាងរដ្ឋាភិបាល និងសង្គមស៊ីវិល DT បានកំណត់ និងអនុវត្តការឆ្លើយតបនានា ដើម្បីលើកស្ទួយលទ្ធភាពទទួលបានអនាគតកាន់តែប្រសើរសម្រាប់កុមារដែលខ្វះខាតបំផុត។

ដើម្បីធានានូវការសម្រេចបានតាមទស្សន និងបេសកកម្មនេះ DT មានការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការៈ

- ពង្រឹងកិច្ចសហការរវាងសហគមន៍កម្ពុជា តំណាងរដ្ឋាភិបាល និងសង្គមស៊ីវិល
- អនុវត្តកម្មវិធីរបស់ខ្លួន ដោយមានការគាំទ្រពីសហគមន៍ តំណាងរដ្ឋាភិបាល និងសង្គមស៊ីវិល ដែលត្រូវបានកែសម្រួលចំពោះកុមារដែលខ្វះខាតបំផុត។
- តស៊ូមតិឲ្យមានការគោរពតម្រូវការជាមូលដ្ឋាន និងសិទ្ធិកុមារ ជាពិសេស សម្រាប់កុមារដែលងាយរងគ្រោះបំផុត។

**គុណតម្លៃរបស់យើង** យើងជាអង្គការមិនមែនសាសនា ពាក់ព័ន្ធនឹងនយោបាយ មិនស្វែងរកផលចំណេញ និងមិនមានការរើសអើង។ ទោះបីជាយ៉ាងណាក៏ដោយ ប្រពៃណីផ្នែកសាសនា ផ្នែកវប្បធម៌ និងផ្នែកប្រវត្តិសាស្ត្រក្នុងស្រុក ត្រូវបានគោរព និងរួមបញ្ចូលទៅក្នុងការងារប្រចាំថ្ងៃ

របស់យើងជាមួយកុមារ។ យើងមិនបដិសេធចំពោះការជះឥទ្ធិពលពីវប្បធម៌ដទៃទៀតឡើយ ប្រសិនបើមានផលប្រយោជន៍ចំពោះគម្រោង។

## *សេចក្តីថ្លែងអំពីការប្តេជ្ញាចិត្ត*

- DT ប្តេជ្ញាចិត្តចំពោះសុខុមាលភាព និងសិទ្ធិរបស់កុមារនៅទូទាំងប្រទេសកម្ពុជា។
- DT ផ្តល់ការឧបត្ថម្ភពេញលេញចំពោះកុមារដែលស្ថិតនៅក្នុងកាលៈទេសៈលំបាក ដើម្បីឲ្យពួកគេអាចអភិវឌ្ឍអនាគតរបស់ពួកគេបាន។ ក្រុមគោលដៅរបស់យើង គឺកុមារដែលមានអាយុក្រោម ១៨ ឆ្នាំ។ DTលើកទឹកចិត្តចំពោះការចែករំលែកព័ត៌មាន និងការផ្សារភ្ជាប់បណ្តាញ ចូលរួមនៅក្នុងគំនិតផ្តួចផ្តើមតស៊ូមតិរួមគ្នា និងសហប្រតិបត្តិការយ៉ាងសកម្មជាមួយទីភ្នាក់ងារដែលធ្វើការនៅក្នុងវិស័យដូចគ្នា។
- DT ប្តេជ្ញាចិត្តក្នុងការគាំទ្រច្បាប់ស្តីពីសិទ្ធិ និងសុខុមាលភាពរបស់កុមារ (ដូចជា អំពើហិង្សាក្នុងគ្រួសារ ពិការភាព)។ ច្បាប់ទាំងនេះរួមបញ្ចូលទាំង*អនុសញ្ញាស្តីពីសិទ្ធិកុមាររបស់អង្គការសហប្រជាជាតិ* ដែលត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជា នៅក្នុងឆ្នាំ១៩៩២ *អនុសញ្ញាស្តីអំពីអាយុអប្បបរមាកុមារដែលធ្វើការ លេខ ១៣៨* ក្នុងឆ្នាំ១៩៩៩ *សេចក្តីប្រកាសស្តីពីជំនួបកំពូលពិភពលោកស្តីពីកុមារ*នៅក្នុងទីក្រុងស្តុកហូម ឆ្នាំ១៩៩៦ និង*មហាសន្និបាតពិភពលោក*បន្ទាប់នៅក្នុងប្រទេសជប៉ុន ឆ្នាំ២០០១ ដែលនាំឲ្យមានផែនការប្រាំឆ្នាំរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារបស់ប្រទេសកម្ពុជា *ប្រឆាំងនឹងការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទកុមារ ពីឆ្នាំ២០០០ ដល់ឆ្នាំ ២០០៤* និង*បទដ្ឋានជាតិអប្បបរមាស្តីពីការថែទាំជំនួសសម្រាប់កុមារ។*
- DT ប្តេជ្ញាលើកទឹកចិត្តបុគ្គលិករបស់ខ្លួនទាំងអស់ក្នុងការប្រព្រឹត្តចំពោះកុមារដោយការគោរព និងភាពថ្លៃថ្នូរ។ អ្នកថែទាំកុមារត្រូវធ្វើជាគំរូល្អ ចំណាយពេលនៅជាមួយកុមារនីមួយៗ យកចិត្តទុកដាក់ចំពោះពួកគេ ស្តាប់ពួកគេ លើកទឹកចិត្តពួកគេ នៅពេលពួកគេប្រព្រឹត្តបានល្អ និងផ្តល់ការពន្យល់ល្អៗដល់ពួកគេ។ អ្នកថែទាំកុមារគួររក្សាពាក្យសន្យារបស់ខ្លួន និងគួរដាក់ពិន័យតែតាមរយៈពាក្យសម្តីសមស្របប៉ុណ្ណោះ។

## *អង្គការតំណក់ទឹកហាមឃាត់គ្រប់ទម្រង់នៃការរំលោភបំពានលើកុមារ*

- កុមារគ្រប់រូបមានសិទ្ធិស្មើៗគ្នាក្នុងការទទួលបានការការពារពការរំលោភបំពាន ដោយមិនប្រកាន់ពូជសាសន៍ សាវតារសង្គម អាយុ ភេទ ពណ៌សម្បុរ ពិការភាព សាសនា ឬជំនឿឡើយ។
- ការរំលោភបំពានលើកុមារ គឺមិនអាចទទួលយកបានឡើយ។ ការដឹងថា កុមារទទួលរងការរំលោភបំពាន ហើយមិនបានចាត់វិធានការសមស្របក៏មិនអាចទទួលយកបានដែរ។
- DT កំណត់ប្រភេទនៃការរំលោភបំពានលើកុមារដូចខាងក្រោម៖

*ការរំលោភបំពានផ្នែករាងកាយ* ទណ្ឌកម្ម និងការរំលោភបំពានផ្នែករាងកាយកុមារ ដូចជា ការវាយដំ (រួមមាន ការប្រើដំបង ឬវត្ថុដទៃទៀត) ការបំពុល ការអង្រួន ការច្រាន និងសកម្មភាពដទៃទៀតដែលមានចេតនាបង្ករបួសដល់សុខុមាលភាពផ្នែករាងកាយរបស់កុមារ។

*ការរំលោភបំពានផ្នែកផ្លូវចិត្ត ឬផ្លូវអារម្មណ៍* សកម្មភាពណាមួយ (កាយវិការ ពាក្យសម្តី និងអាកប្បកិរិយា) ដែលមានចេតនាធ្វើឲ្យមានផលប៉ះពាល់ចំពោះសុខុមាលភាពផ្លូវចិត្ត ឬផ្លូវអារម្មណ៍របស់កុមារ ឧទាហរណ៍ ការធ្វើឲ្យពួកគេមានភាពភ័យខ្លាច ថប់បារម្ភ មួរម៉ៅ ឬអស់ទឹកចិត្ត។

*ការមិនអើពើ* សកម្មភាពដែលមានបំណងធ្វើឲ្យប៉ះពាល់ដល់សិទ្ធិសំខាន់ៗទាំងបួនរបស់កុមារដោយចេតនា (សិទ្ធិរស់រានមានជីវិត សិទ្ធិទទួលការអប់រំ សិទ្ធិចូលរួម និងសិទ្ធិបញ្ចេញមតិ)។

*ការរំលោភបំពានផ្លូវភេទ* សកម្មភាពដែលមានបំណងផ្លូវភេទចំពោះកុមារ ដូចជា ការប៉ះប្រដាប់ភេទរបស់កុមារ ការបង្ខំកុមារឲ្យរួមភេទ ឬការបង្ខំកុមារឲ្យមើល ឬចូលរួមក្នុងភាពយន្ត/រូបភាពអាសអាភាស។

*ការរំលោភបំពានផ្នែកស្មារតី* សកម្មភាពណាមួយដែលធ្វើឡើងដោយអ្នកដឹកនាំផ្នែកស្មារតី ឬអ្នកដែលមានអំណាច ឬសិទ្ធិអំណាចផ្នែកស្មារតី (ទោះជាអង្គការ ស្ថាប័ន ឬក្រុមគ្រួសារក្តី) ការប្រើប្រាស់អំណាច ឬសិទ្ធិអំណាចរបស់ពួកគេក្នុងផ្លូវខុស ដោយមានចេតនា ត្រួតត្រា បង្ខំ ប្រើប្រាស់ ឬគ្រប់គ្រងកុមារណាម្នាក់។ ការរំលោភបំពានផ្នែកស្មារតី នឹងបណ្តាលឲ្យមានការប៉ះពាល់ផ្នែកស្មារតីដល់កុមារ។

## *ក្រមនៃការអនុវត្ត និងអាកប្បកិរិយា*

- គេមានសេចក្តីរំពឹងទុកយ៉ាងខ្លាំងចំពោះបុគ្គលិក អ្នកស្ម័គ្រចិត្ត អ្នកមកធ្វើទស្សនកិច្ច ម្ចាស់ជំនួយ ភ្ញៀវ ឬភាគីពាក់ព័ន្ធដទៃទៀតទាំងអស់របស់ DT ក្នុងការប្រព្រឹត្តចំពោះកុមារទាំងអស់ និងបុគ្គលិកដទៃទៀតប្រកបដោយការគោរព និងភាពថ្លៃថ្នូរ។
- បុគ្គលិកគួរតែផ្សព្វផ្សាយអំពីវប្បធម៌នៃការបើកទូលាយ ដែលគេអាចលើកឡើង និងពិភាក្សាអំពីបញ្ហា និងកង្វល់នានា។
- បុគ្គលនីមួយៗត្រូវចុះហត្ថលេខាលើសេចក្តីបញ្ជាក់អះអាងថា ពួកគេបានអានគោលនយោបាយការពារកុមារ និងគោរពតាមគោលនយោបាយនេះ និងយល់ថា វិធានការណាមួយនឹងត្រូវបានធ្វើឡើងក្នុងករណីដែលមានអាកប្បកិរិយាមិនសមរម្យ។
- មានបុគ្គលដែលត្រូវបានគេចាត់តាំងមួយរូបដែលទទួលខុសត្រូវដោះស្រាយចំពោះបញ្ហាការពារកុមារនៅក្នុងអង្គការទាំងមូល។ ក្រៅពីនេះ នៅក្នុងទីតាំងជាក់លាក់នីមួយៗ

ក៏មានមន្ត្រីការពារកុមារ (CPO) ដែលទទួលខុសត្រូវចំពោះការដោះស្រាយចំពោះបញ្ហាការពារកុមារផងដែរ។ កុមារ និងបុគ្គលិកទាំងអស់គួរតែស្គាល់បុគ្គលទាំងនេះ។

- គេត្រូវធ្វើការណែនាំអំពីព័ត៌មានស្តីអំពីគោលនយោបាយការពារកុមារនៅមុនពេល និងនៅពេលទទួលបុគ្គលិកណាម្នាក់ឲ្យចូលបម្រើការងារនៅក្នុង DT។
- បុគ្គលិកថ្មីនឹងទទួលបានការបណ្តុះបណ្តាលស្តីអំពីការការពារកុមារ មុនពេលចូលបម្រើការងារនៅក្នុងមុខតំណែងដែលមានសេចក្តីទុកចិត្ត បុគ្គលិកនឹងទទួលបានការបណ្តុះបណ្តាលបំប៉នជារៀងរាល់ឆ្នាំ ដែលបង្កើតឡើងដោយមន្ត្រីការពារកុមារ។
- ការការពារកុមារនឹងក្លាយជាចំណុចមួយនៃការពិភាក្សាវាយតម្លៃបុគ្គលិកថ្មីនៅពេលបញ្ចប់រយៈពេលសាកល្បងរបស់ពួកគេ។
- ការការពារកុមារនឹងក្លាយជាចំណុចមួយនៃការពិភាក្សាវាយតម្លៃបុគ្គលិកប្រចាំឆ្នាំ។
- ប្រសិនបើមានការរំលោភបំពានលើនីតិវិធីទាំងនេះ បុគ្គលដែលពាក់ព័ន្ធនឹងទទួលវិធានការវិន័យ និងអាចបាត់បង់ការងាររបស់ខ្លួន។
- បុគ្គលិកគួរយល់ដឹងអំពីសញ្ញានៃការរំលោភបំពានលើកុមារ (ការលេចឡើងផ្នែករាងកាយ អាកប្បកិរិយា ការកាន់កាប់សម្ភារៈ និងការប្រាស្រ័យទាក់ទងរបស់កុមារ) និងរាយការណ៍រាល់ការសង្ស័យទៅកាន់ CPO។
- បុគ្គលិក និងជនដទៃទៀតអាចដាក់ពិន័យបានតែតាមរយៈការប្រើពាក្យសម្តីសមរម្យតែប៉ុណ្ណោះ និងមិនត្រូវប្រើប្រាស់វិធីសាស្ត្រដែលប៉ះពាល់ដល់រាងកាយកុមារឡើយ។
- បុគ្គលិក និងជនដទៃទៀតមិនត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ភាសា ធ្វើការស្នើសុំ ឬផ្តល់ជំនូន្មានប្រភេទណាមួយដែលមានការប្រមាថមើលងាយ មិនសមរម្យ ឬមានលក្ខណៈរំលោភបំពានឡើយ។
- ដើម្បីកំណត់ព្រំដែនផ្នែករាងកាយដ៏សមស្រប គេមិនត្រូវប៉ះពាល់កុមារដោយប្រើវិធីសាស្ត្រណាមួយដែលប្រឆាំងនឹងអនុសញ្ញាស្តីអំពីសិទ្ធិកុមារនោះឡើយ។ គោលការណ៍ណែនាំជាទូទៅ នោះគឺ មិនត្រូវប៉ះពាល់ផ្នែកណាមួយ ដែលជាធម្មតា ត្រូវបានគ្របដណ្តប់ដោយខោខ្លី និងអាវយឺត។ នេះរួមបញ្ចូលទាំងការថើប ការម៉ាស្សា ឬចាក់ក្រឡេកតាមរបៀបមួយដែលមិនសមស្រប។
    - មានករណីលើកលែងទាក់ទងនឹងមជ្ឈមណ្ឌល DT សម្រាប់ជនពិការនៅទីក្រុងភ្នំពេញ។ ដោយសារកុមារមានតម្រូវការពិសេសជាច្រើន ដូច្នេះបុគ្គលិកត្រូវជួយដល់កុមារទាំងនេះក្នុងការថែរក្សាអនាម័យជាមូលដ្ឋានរបស់ពួកគេ (ការងូតទឹក ការប្រើប្រាស់បង្គន់ ។ល។) អ្នកថែទាំកុមារត្រូវធ្វើបែបនេះ ដោយមានការគោរពចំពោះពិការភាព ភាពឯកជន និងសេចក្តីថ្លៃថ្នូររបស់កុមារ។
- បុគ្គលិក និង បុគ្គលដទៃទៀតមិនត្រូវធ្វើអ្វីសម្រាប់កុមារដែលមានលក្ខណៈផ្ទាល់ខ្លួនដែលកុមារអាចធ្វើបានសម្រាប់ខ្លួនឯង។

- បុគ្គលិក និងបុគ្គលដទៃទៀតមិនត្រូវបង្កើតទំនាក់ទំនងផ្លូវភេទជាមួយកុមារនោះឡើយ។
- បុគ្គលិក និងបុគ្គលដទៃទៀតមិនត្រូវបានអនុញ្ញាតឲ្យនៅតែឯងជាមួយកុមារនៅក្នុងតំបន់គម្រោង ឬនៅក្រៅតំបន់គម្រោងឡើយ។ ប្រសិនបើបុគ្គលណាម្នាក់នៅតែឯងជាមួយកុមារ គាត់គួរត្រូវបានមើលឃើញដោយអ្នកដទៃជានិច្ច។ ប្រសិនបើវាពាក់ព័ន្ធនឹងការជួបជាលក្ខណៈឯកជន ពួកគេត្រូវជួបគ្នានៅទីសាធារណៈ ឬនៅក្នុងការិយាល័យដោយបើកបង្អួច និងជូនដំណឹងដល់អ្នកសម្របសម្រួលគម្រោង ឬសមាជិកដទៃទៀតនៃគណៈគ្រប់គ្រង នៅពេល និងនៅកន្លែងដែលការជួបគ្នានោះប្រព្រឹត្តទៅ។
- បុគ្គលិក អ្នកស្ម័គ្រចិត្ត អ្នកមកធ្វើទស្សនិក និងភ្ញៀវដទៃទៀត មិនត្រូវបានអនុញ្ញាតឲ្យនាំយកកុមារដែលមិនមែនជាកូនរបស់ពួកគេទៅកាន់កន្លែងស្នាក់នៅរបស់ខ្លួនឡើយ។
- ចំពោះកុមារដែលស្នាក់នៅមណ្ឌល បុគ្គលិកមិនត្រូវបានអនុញ្ញាតឲ្យនាំយកកុមារចេញពីមណ្ឌលដោយគ្មានការអនុញ្ញាតពីអ្នកគ្រប់គ្រងផ្ទាល់នីមួយៗឡើយ។
- ចំពោះកុមារដែលស្នាក់នៅមណ្ឌល សាច់ញាតិត្រូវបានអនុញ្ញាតឲ្យមកសួរសុខទុក្ខកូនរបស់ពួកគេនៅមណ្ឌល ប៉ុន្តែមិនអនុញ្ញាតឲ្យស្នាក់នៅពេលយប់ ឬនាំកុមារចេញក្រៅមណ្ឌលឡើយ។
- មនុស្សពេញវ័យទទួលខុសត្រូវជានិច្ចចំពោះអាកប្បកិរិយារបស់ខ្លួន និងមិនអាចស្តីបន្ទោសកុមារបានឡើយ ទោះបីជាកុមារធ្វើឲ្យពួកគេខឹង ឬធ្វើសកម្មភាពទាក់ទាញណាមួយក៏ដោយ។
- បុគ្គលិក និងបុគ្គលដទៃទៀតមិនត្រូវធ្វើសកម្មភាពដែលធ្វើឲ្យអាម៉ាស ប្រមាថ ឬមាក់ងាយ ឬប្រើប្រាស់ទម្រង់ផ្សេងៗទៀតនៃការរំលោភបំពានផ្នែកអារម្មណ៍ឡើយ។
- បុគ្គលិកមិនគួរបង្កើតភាពពឹងផ្អែក និងការរើសអើសចំពោះកុមារ តាមរយៈការប្រព្រឹត្តលម្អៀង ដូចជា ការផ្តល់អំណោយ ឬប្រាក់កាសឡើយ។
- បុគ្គលិកគួរតែរៀបចំសិក្ខាសាលាលើកកម្ពស់ការយល់ដឹងជាមួយកុមារ ដើម្បីកំណត់អាកប្បកិរិយាដែលអាចទទួលយកបាន និងមិនអាចទទួលយកបានជាមួយមនុស្សពេញវ័យ។
- សហគមន៍ និងកុមារ ដែល DT ធ្វើការងារជាមួយ ត្រូវជ្រាបអំពីគោលនយោបាយការពារកុមារ ហើយនឹងត្រូវបានធានាថា ការគាំទ្រនឹងមិនត្រូវបានកាត់ផ្តាច់ឡើយប្រសិនបើពួកគេរាយការណ៍អំពីអាកប្បកិរិយាដែលគួរឲ្យសង្ស័យ។
- ឯកសារស្តីអំពីការគ្រប់គ្រងករណី និងកំណត់ត្រារបស់កុមារ គឺជាព័ត៌មានសម្ងាត់បំផុត (សូមមើលគោលនយោបាយបុគ្គលិក) និងត្រូវបានរក្សាទុកនៅកន្លែងដែលមានសុវត្ថិភាព។ ការចូលមើលឯកសារទាំងនេះ អាចធ្វើទៅបាន លុះត្រាតែមានការអនុញ្ញាតពី ED និងអ្នកសម្របសម្រួលនីមួយៗប៉ុណ្ណោះ។

- ករណីសិក្សាត្រូវបានផ្ដល់ឲ្យតែនៅក្រោយពេលមានការអនុញ្ញាតពីអ្នកសម្របសម្រួលនីមួយៗប៉ុណ្ណោះ។ ករណីសិក្សាត្រូវបានរក្សាទុកជាអនាមិកជានិច្ច។
- រាល់អ្នកធ្វើទស្សនកិច្ចត្រូវចុះហត្ថលេខាលើលក្ខខណ្ឌបន្ថែមសម្រាប់ការធ្វើទស្សនកិច្ចគម្រោងរបស់ DT។ លក្ខខណ្ឌទាំងនោះមាននៅក្នុងឧបសម្ព័ន្ធទី ២។
- រាល់អ្នកសារព័ត៌មានគួរតែចុះហត្ថលេខាលើសេចក្ដីណែនាំបន្ថែមរបស់ DT សម្រាប់អ្នកសារព័ត៌មាន។ វាមាននៅក្នុងឧបសម្ព័ន្ធទី ៣។
- រាល់អ្នកស្ម័គ្រចិត្តអន្តរជាតិត្រូវអនុលោមតាមគោលនយោបាយបន្ថែមដែលមាននៅក្នុងឧបសម្ព័ន្ធទី ៤។
- រាល់អ្នកធ្វើទស្សនកិច្ច អ្នកសារព័ត៌មាន និងអ្នកស្ម័គ្រចិត្តទាំងអស់គួរតែយល់ដឹងអំពីការកំហិតលើការថតរូប និងការថតជាខ្សែភាពយន្ត។
  - មិនគួរថតរូបដោយគ្មានការអនុញ្ញាតពីបុគ្គលិក និងការយល់ព្រមរបស់កុមារឡើយ។
  - យោងតាមច្បាប់ស្ដីពីការជួញដូរ សារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយដទៃទៀតត្រូវបានហាមឃាត់មិនឲ្យបោះពុម្ពផ្សាយ ឬផ្សព្វផ្សាយណាមួយ ដែលអាចនាំឲ្យសាធារណជនស្គាល់អត្តសញ្ញាណរបស់ជនរងគ្រោះនៅក្នុងបទល្មើស ដែលមានចែងនៅក្នុងច្បាប់នេះ។
  - មិនគួរលើកឡើងអំពីឈ្មោះពេញរបស់កុមារនៅក្នុងការបោះពុម្ពផ្សាយ ឬការផ្សព្វផ្សាយណាមួយឡើយ។
  - ការថតរូបកុមារអាក្រាតកាយ ឬពាក់កណ្ដាលអាក្រាតត្រូវបានហាមឃាត់ដាច់ខាត។
  - សំណៅចម្លងនៃរូបថត និងវីដេអូច្បាប់ដើមគួរតែចែករំលែកជាមួយ DT។

## *ការជ្រើសរើស និងការសម្រាំង*

DT រំពឹងទុកថា បុគ្គលិកទាំងអស់នឹងការពារកុមារពីការរំលោភបំពាន ហើយនឹងត្រូវបានសម្រាំងមុនពេលចាប់ផ្ដើមការងារ។ ការសម្រាំងមានសារសំខាន់ស្មើៗគ្នាចំពោះអ្នកស្ម័គ្រ/អ្នកហាត់ការ សមាជិកក្រុមប្រឹក្សា និងទីប្រឹក្សា (ក្នុងស្រុក និងបរទេស)។ អ្នកដាក់ពាក្យសុំធ្វើការក្នុងមុខតំណែងណាមួយជាមួយ DT ត្រូវដាក់ពាក្យសុំ ឬប្រវត្តិរូបសង្ខេប រួមទាំងប្រវត្តិការងារ និងប្រវត្តិផ្ទាល់ខ្លួន។នៅពេលដាក់ពាក្យសុំធ្វើការក្នុងមុខតំណែងណាមួយ ពាក្យសុំត្រូវចុះហត្ថលេខាដោយយល់ព្រមលើគោលនយោបាយការពារកុមារ និងបញ្ជាក់ថា ខ្លួនមិនធ្លាប់មានទោសកំហុសកាលពីមុនដែលពាក់ព័ន្ធនឹងការរំលោភបំពានលើកុមារ ឬអាកប្បកិរិយាហិង្សាណាមួយ ឬធ្លាប់ត្រូវបានបញ្ឈប់ពីការងារដោយសារការរំលោភបំពានណាមួយឡើយ។
បុគ្គលអះអាងអាកប្បកិរិយា នឹងត្រូវបានសាកសួរតាមរយៈទូរស័ព្ទ ដើម្បីផ្ដល់ឱកាសឲ្យនិយោជកមុនៗបង្ហាញអំពីកង្វល់របស់ពួកគេ តាមរយៈពាក្យសម្ដី។ ប្រសិនបើយល់ឃើញថា

ចាំបាច់ DT អាចស្នើសុំលិខិតបញ្ជាក់កិរិយាមាយាទជាផ្លូវការ (ដោយក្រសួងយុត្តិធម៌ ឬអាជ្ញាធរមូលដ្ឋាន)។ បន្ទាប់ពីផ្ទៀងផ្ទាត់បុគ្គលអះអាងអាកប្បកិរិយារួច ការសម្ភាសន៍ផ្ទាល់ខ្លួនមួយនឹងត្រូវបានធ្វើឡើង ដើម្បីអះអាងអំពីភាពស័ក្តិសមរបស់បេក្ខជន។ ប្រសិនបើនៅក្រោយពេលជ្រើសរើសរួចរាល់ហើយ ហើយត្រូវបានគេរកឃើញថា និយោជិតនោះបានផ្តល់ព័ត៌មានមិនពិត និងពិតជាធ្លាប់ប្រព្រឹត្តកំហុសនៃការរំលោភបំពានលើកុមារ ឬអាកប្បកិរិយាហិង្សា ឬធ្លាប់ត្រូវបានបណ្តេញចេញពីការងារដោយសារការរំលោភបំពាននោះ នឹងនាំឲ្យមានការបញ្ឈប់ពីការងារជាបន្ទាន់។

***ការទំនាក់ទំនងអំពីការការពារ និងការរំលោភបំពានលើកុមារ***

*ខាងក្រៅ*

- DT មានការប្តេជ្ញាចិត្តចំពោះការជូនដំណឹងដល់កុមារ អ្នកធ្វើសេចក្តីសម្រេចចិត្ត និងសាធារណជន ក៏ដូចជាតាមប្រព័ន្ធផ្សព្វផ្សាយថា ការរំលោភបំពានលើកុមារ និងការមិនអើពើក្នុងករណីដឹងឮអំពីការរំលោភបំពានលើកុមារ គឺជាទង្វើខុសឆ្គង និងមិនអាចទទួលយកបានឡើយ។
- បុគ្គលិកមិនគួរផ្តល់យោបល់អំពីបញ្ហាការពារកុមារនៅតាមប្រព័ន្ធផ្សព្វផ្សាយដោយគ្មានការប្រឹក្សាជាមួយនាយកប្រតិបត្តិ និងគណៈកម្មាធិការប្រតិបត្តិជាមុនឡើយ។
- គោលនយោបាយការពារកុមារនេះមានគោលបំណងអនុញ្ញាតឲ្យមានបរិយាកាសដែលមានសុវត្ថិភាព និងវិជ្ជមានសម្រាប់កុមារ និងជាមូលដ្ឋានគ្រឹះនៅក្នុងគំនិតផ្តួចផ្តើមសម្រាប់ការអប់រំ ការស្រាវជ្រាវ និងការតស៊ូមតិ ដែល DT នឹងចូលរួម។
- DT មានការប្តេជ្ញាចិត្តចំពោះការអប់រំ និងការជូនដំណឹងដល់ភាគីពាក់ព័ន្ធរបស់ខ្លួនអំពីសារៈសំខាន់នៃការអនុវត្តវិធានការទប់ស្កាត់ស្តីពីការការពារកុមារ។ តាមរយៈការធ្វើដូច្នេះ កុមារនឹងត្រូវបានការពារពីការរំលោភបំពាន ដែលអាចសម្រេចបានតាមរយៈបុគ្គលិក អ្នកស្ម័គ្រចិត្ត អ្នកធ្វើទស្សនកិច្ច និងបុគ្គលដទៃទៀតដែលចូលរួមនៅក្នុង DT។

*ខាងក្នុង*

- DT ផ្តល់ឱកាសដល់កិច្ចប្រជុំផ្ទៃក្នុងដើម្បីពិភាក្សា និងស្វែងយល់អំពីការរំលោភបំពានលើកុមារ និងភាពមិនអើពើជាមួយបុគ្គលិករបស់ខ្លួនទាំងអស់។ DT ក៏ប្តេជ្ញាលើកឡើង និងពិភាក្សាអំពីបញ្ហាទាំងនេះនៅក្នុងកិច្ចប្រជុំជាមួយដៃគូ និងបណ្តាញដទៃទៀតផងដែរ។
- បុគ្គលិកថ្មីរបស់ DT នឹងទទួលបានការបណ្តុះបណ្តាលអំពីការការពារកុមារនៅមុនពេលចូលបម្រើក្នុងមុខតំណែងដែលមានសេចក្តីទុកចិត្ត បុគ្គលិកនឹងទទួលការបណ្តុះបណ្តាលបំប៉នរៀងរាល់ឆ្នាំ ដែលធ្វើឡើងដោយមន្ត្រីការពារកុមារ។
- បុគ្គលិក និងអ្នកស្ម័គ្រចិត្តទាំងអស់ នឹងទទួលបានសំណៅចម្លងមួយច្បាប់នៃគោលនយោបាយការពារកុមារ នៅពេលពួកគេចុះកិច្ចសន្យាជាមួយ DT។

- DT ប្តេជ្ញាចិត្តក្នុងការពិភាក្សាអំពីសិទ្ធិកុមារ និងការរំលោភបំពានលើកុមារនៅក្នុងសហគមន៍ ដែលពួកគេកំពុងធ្វើការ រួមទាំងការពិភាក្សាជាមួយកុមារដោយផ្ទាល់ផងដែរ។
- នៅក្នុងគម្រោងជាច្រើនរបស់ DT កុមារនឹងស្វែងយល់អំពីសិទ្ធិរបស់ពួកគេ និងអ្នកដែលពួកគេអាចនិយាយទៅកាន់នៅពេលដែលមានករណីរំលោភបំពាន។
- រាល់គម្រោងនៅក្នុង DT ទាំងអស់ នឹងមានវិធីសាស្ត្រសម្រាប់កុមារក្នុងការចូលរួមបង្ហាញអំពីការទាមទារ និងកង្វល់របស់ពួកគេចំពោះការរំលោភបំពានដោយអនាមិក។

## *ការឆ្លើយតបទៅនឹងការចោទប្រកាន់ចំពោះការរំលោភបំពានលើកុមារ*

- នីតិវិធីនានាត្រូវបានកំណត់ដោយ DT ដើម្បីធានាថា បុគ្គលិកទាំងអស់ដឹងអំពីអ្វីដែលត្រូវធ្វើ ប្រសិនបើមានការចោទប្រកាន់ថា មានការរំលោភបំពានលើកុមារបានកើតឡើង មិនថា ដោយកុមារ ឪពុកម្តាយ បុគ្គលិក ឬអ្នកធ្វើទស្សនកិច្ច ឬបុគ្គលដទៃទៀតដែលពាក់ព័ន្ធឡើយ។ នេះរួមបញ្ចូលទាំងការបណ្តុះបណ្តាលអំពីគោលនយោបាយការពារកុមារ និងការមានតារាងព័ត៌មានដែលបុគ្គលិកទាំងអស់អាចមើលឃើញ។ នីតិវិធីទាំងនេះត្រូវបានផ្សព្វផ្សាយដល់បុគ្គលិកនៅក្រោយពេលចុះកិច្ចសន្យា និងនៅអំឡុងពេលនៃការផ្តល់ការបណ្តុះបណ្តាលបំប៉នអំពីការការពារកុមារជារៀងរាល់ឆ្នាំ។
- មានបុគ្គលចាត់តាំងមួយរូបដែលទទួលខុសត្រូវដោះស្រាយចំពោះបញ្ហាការពារកុមារនៅទីតាំងនីមួយៗ គឺមន្ត្រីការពារកុមារ (CPO) ។ កុមារ និងបុគ្គលិកទាំងអស់គួរតែស្គាល់បុគ្គលទាំងនេះ។
- DT លើកទឹកចិត្តបុគ្គលិកទាំងអស់ឲ្យគោរពច្បាប់នៃប្រទេសកម្ពុជា រួមទាំងច្បាប់ការងារផងដែរ។
- បុគ្គលិករបស់ DT ទាំងអស់ត្រូវបានលើកទឹកចិត្តឲ្យមានការបើកទូលាយក្នុងការពិភាក្សាអំពីសក្តានុពលនៃការរំលោភបំពាននៅក្នុងអង្គការ និងយកចិត្តទុកដាក់យ៉ាងម៉ត់ចត់ចំពោះកង្វល់ដែលត្រូវបានលើកឡើង។
- បុគ្គលិកដែលដឹងអំពីបុគ្គលិកផ្សេងទៀតដែលបានចូលរួមនៅក្នុងការរំលោភបំពានកុមារមានកាតព្វកិច្ចរាយការណ៍ទៅកាន់មន្ត្រីការពារកុមារ។ ប្រសិនបើរកឃើញថា ខ្លួនមិនបានរាយការណ៍ទេនោះ វិធានការសមស្របនឹងត្រូវបានធ្វើឡើង។
- នៅពេលការចោទប្រកាន់អំពីការរំលោភបំពានលើកុមារត្រូវបានធ្វើឡើងប្រឆាំងនឹងបុគ្គលិក ឬអ្នកធ្វើទស្សនកិច្ចណាម្នាក់ DT នឹងធ្វើការស៊ើបអង្កេតអំពីការចោទប្រកាន់នេះ និងចាត់វិធានការសមស្របជាបន្ទាន់ ដើម្បីដោះស្រាយចំពោះស្ថានភាពនេះ។
- ជំហានវិជ្ជមាននឹងត្រូវបានធ្វើឡើងដើម្បីធានាចំពោះការការពារ និងការថែទាំដែលត្រូវផ្តល់ដល់កុមារដែលពាក់ព័ន្ធនឹងសេចក្តីព្រួយបារម្ភទាំងនេះ។

- ទាំងជនរងគ្រោះ ទាំងជនប្រព្រឹត្ត ដែលត្រូវបានចោទប្រកាន់ នឹងត្រូវបានប្រព្រឹត្តប្រកបដោយសេចក្តីគោរព ចាប់តាំងពីពេលចាប់ផ្តើមដំណើរការរហូតដល់ពេលបញ្ចប់។
- រឿងរ៉ាវរបស់កុមារនឹងត្រូវបានវិនិច្ឆ័យ និងយកចិត្តទុកដាក់យ៉ាងម៉ត់ចត់ លើកលែងតែត្រូវបានបង្ហាញផ្សេងពីនេះ។
- អង្គការមាននីតិវិធីនៃការរាយការណ៍ដែល CPO នឹងជូនដំណឹងដល់នាយកប្រតិបត្តិ គណៈកម្មាធិការប្រតិបត្តិ និងអ្នកសម្របសម្រួលនីមួយៗ និងបុគ្គលដទៃទៀត លុះត្រាតែមានការចាំបាច់នៅក្នុងនីតិវិធីប៉ុណ្ណោះ។ ការរាយការណ៍ គឺមានភាពសម្ងាត់ទាំងស្រុង។
- រាល់ការណ៍ដែលពាក់ព័ន្ធនឹងការស៊ើបអង្កេតគួរតែធ្វើការរាយការណ៍ ហើយគេនឹងតម្កល់ទុកឯកសារទាំងនេះដោយប្រុងប្រយ័ត្ន និងដោយសម្ងាត់។ សូមមើលឧបសម្ព័ន្ធទី ១ សម្រាប់ទម្រង់បែបបទរាយការណ៍ដែលត្រូវបំពេញ។
- អ្នកប្រព្រឹត្តដែលត្រូវបានចោទប្រកាន់ មិនត្រូវបានអនុញ្ញាតឲ្យធ្វើការទំនាក់ទំនងជាមួយកុមារ ឬសាច់ញាតិរបស់កុមារនៅអំឡុងពេលនៃការស៊ើបអង្កេតឡើយ។
- អ្នកប្រព្រឹត្តដែលត្រូវបានគេចោទប្រកាន់ ត្រូវបានផ្អាកពីការងារនៅអំឡុងពេលនៃការស៊ើបអង្កេត។
- ប្រសិនមានពាក់ព័ន្ធនឹងជនបរទេស ស្ថានទូត/ស្ថានកុងស៊ុលដែលពាក់ព័ន្ធនឹងត្រូវបានជូនដំណឹង។
- បុគ្គលម្នាក់នៅក្នុងអង្គការ នឹងត្រូវបានចាត់តាំងដើម្បីទំនាក់ទំនងជាមួយប្រព័ន្ធផ្សព្វផ្សាយ និងនគរបាល។ គណៈគ្រប់គ្រងនៅក្នុងទីតាំងនីមួយៗ នឹងសម្រេចចំពោះការចាត់តាំងបុគ្គលនេះ។ ប្រសិនបើអាច គេនឹងធ្វើការពិចារណាជាមុនអំពីរបៀបដែលពួកគេត្រូវបានជូនដំណឹង/ពាក់ព័ន្ធ។
- គេនឹងជូនដំណឹងដល់បុគ្គលដែលពាក់ព័ន្ធទាំងអស់អំពីលទ្ធផលនៃការស៊ើបអង្កេត និងសកម្មភាពណាមួយដែលត្រូវអនុវត្តដែលជាលទ្ធផលនៃការស៊ើបអង្កេតនោះ។
- នៅពេលដែលគេរកឃើញថា ការចោទប្រកាន់នោះ គឺជាការពិត គេនឹងជូនដំណឹងដល់អាជ្ញាធរពាក់ព័ន្ធ។
- ប្រសិនបើគេរកឃើញថា ការចោទប្រកាន់នោះ គឺមិនពិត DT នឹងផ្តល់ការគាំទ្រដ៏សមស្របចំពោះបុគ្គលដែលពាក់ព័ន្ធនៅក្នុងការដោះស្រាយចំពោះការចោទប្រកាន់នេះ និងផលវិបាករបស់វា។
- DTលើកទឹកចិត្តចំពោះទំនាក់ទំនង/កិច្ចសហការជាមួយអង្គការដទៃទៀតសម្រាប់ គណនេយ្យភាព និងការគាំទ្រនៅក្នុងករណីមានការរំលោភបំពានលើកុមារ ប្រសិនបើចាំបាច់។

- នៅពេលដែលមានការទំនាក់ទំនងពីអង្គការដែលមិនមានបទពិសោធន៍ និងស្នើសុំជំនួយពីអង្គការសិទ្ធិកុមារដទៃទៀត DT នឹងឆ្លើយតបទៅនឹងតម្រូវការរបស់ពួកគេតាមសមត្ថភាពដែលខ្លួនមាន។

**កិច្ចព្រមព្រៀង និងការយល់ព្រមចំពោះការបញ្ចេញព័ត៌មាន**

ខ្ញុំបានអាន និងយល់អំពីលក្ខខណ្ឌនៃគោលនយោបាយនេះ ហើយខ្ញុំយល់ព្រមគោរពតាមសេចក្តីណែនាំនៃគោលនយោបាយនេះ។ ខ្ញុំសូមប្រកាសថា ខ្ញុំមិនធ្លាប់មានប្រវត្តិប្រព្រឹត្តបទឧក្រិដ្ឋណាមួយដែលពាក់ព័ន្ធនឹងកុមារនៅក្នុងប្រទេសកម្ពុជា ឬនៅក្រៅប្រទេសឡើយ ហើយខ្ញុំអនុញ្ញាតឲ្យ DT ធ្វើការត្រួតពិនិត្យសារតារ/បុគ្គលអះអាងអាកប្បកិរិយា ដើម្បីផ្ទៀងផ្ទាត់ការអះអាងនេះ។

ខ្ញុំយល់ថា ប្រសិនបើមានការប្តឹងទាក់ទងនឹងប្រភេទណាមួយនៃការរំលោភបំពានលើកុមារខណៈពេលដែលចូលរួមក្នុងសកម្មភាពរបស់ DT គេនឹងធ្វើការស៊ើបអង្កេតយ៉ាងម៉ត់ចត់ ដោយសហការជាមួយអាជ្ញាធរដែលសមស្រប ហើយខ្ញុំយល់ព្រមទទួលផលវិបាកសមស្រប។

ខ្ញុំយល់ថា ប្រសិនបើខ្ញុំមានទោសកំហុសណាមួយនៃការរំលោភបំពាន ឬការមិនអើពើផ្នែករាងកាយ អារម្មណ៍ ផ្លូវភេទ និងស្មារតី ខ្ញុំនឹងបាត់បង់ការងាររបស់ខ្ញុំដោយគ្មានសិទ្ធិធ្វើអ្វីមួយឡើយ។

ខ្ញុំយល់ថា ប្រសិនបើខ្ញុំមិនរាយការណ៍អំពីសេចក្តីសង្ស័យនៃការរំលោភបំពានណាមួយដែលពាក់ព័ន្ធនឹងបុគ្គលិក អ្នកស្ម័គ្រចិត្ត អ្នកហាត់ការ អ្នកមកធ្វើទស្សនកិច្ច និងដៃគូទេនោះ ខ្ញុំអាចទទួលរងផលវិបាកសមស្រប ដូចជា ការបាត់បង់ការងាររបស់ខ្ញុំដោយគ្មានសិទ្ធិអ្វីទាំងអស់។

| | |
|---|---|
| បុគ្គលិក/អ្នកស្ម័គ្រចិត្ត/អ្នកសម្របសម្រួល | មន្ត្រីការពារកុមារ/អ្នកសម្របសម្រួលគម្រោង |
| ហត្ថលេខា | ហត្ថលេខា |
| ............................................................ | ............................................................ |
| ឈ្មោះ ................................................ | ឈ្មោះ ................................................ |
| កាលបរិច្ឆេទ ......................................... | កាលបរិច្ឆេទ ......................................... |

## ទម្រង់បែបបទនៃការរាយការណ៍ពាក់ព័ន្ធនឹងករណីរំលោភបំពានលើកុមារ

### អ្នករាយការណ៍

ឈ្មោះ៖

មុខតំណែង៖

កន្លែងធ្វើការ៖

ទំនាក់ទំនងរវាងអ្នក និងកុមារ៖

### អំពីកុមារ

ឈ្មោះកុមារ៖

ភេទកុមារ៖

☐ ស្រី ☐ ប្រុស

អាយុកុមារ៖

អាណាព្យាបាលកុមារ៖

### បញ្ហាដែលសម្គាល់ឃើញ

តើអ្នកដឹងអំពីហេតុការណ៍នេះដោយវិធីណា?

☐ *ការអង្កេតដោយផ្ទាល់*

☐ *ការសង្ស័យ*

☐ *ការសារភាពរបស់កុមារ*

☐ *ការសារភាពរបស់អ្នកដទៃ*

កាលបរិច្ឆេទ និងពេលវេលានៃហេតុការណ៍៖

.................................................................................................................................................

.................................................................................................................................................

.................................................................................................................................................

.................................................................................................................................................

.................................................................................................................................................

សេចក្តីលម្អិត៖

.................................................................................................................................................

.................................................................................................................................................

.................................................................................................................................................

.................................................................................................................................................

.................................................................................................................................................

.................................................................................................................................................

.................................................................................................................................................

.................................................................................................................................................

.................................................................................................................................................

ទីតាំងនៃហេតុការណ៍ដែលត្រូវបានចោទប្រកាន់៖

.................................................................................................................................................

.................................................................................................................................................

.................................................................................................................................................

.................................................................................................................................................

.................................................................................................................................................

តើអ្នកណាពាក់ព័ន្ធនឹងហេតុការណ៍នេះ?

.................................................................................................................................................

.................................................................................................................................................

.................................................................................................................................................

.................................................................................................................................................

.................................................................................................................................................

ឈ្មោះអ្នកប្រព្រឹត្តដែលត្រូវបានចោទប្រកាន់៖

...........................................................................................................................................

...........................................................................................................................................

...........................................................................................................................................

...........................................................................................................................................

...........................................................................................................................................

□ បុគ្គលិក (រួមបញ្ចូលទាំងអ្នកស្ម័គ្រចិត្ត ទីប្រឹក្សាបច្ចេកទេស)
ប្រសិនបើជាបុគ្គលិក តើមានមុខតំណែងអ្វី៖

□ បុគ្គលខាងក្រៅ
ប្រសិនបើជាបុគ្គលខាងក្រៅ តើមានទំនាក់ទំនងអ្វីជាមួយកុមារ៖

លក្ខណៈនៃការចោទប្រកាន់៖

...........................................................................................................................................

...........................................................................................................................................

...........................................................................................................................................

...........................................................................................................................................

...........................................................................................................................................

...........................................................................................................................................

...........................................................................................................................................

...........................................................................................................................................

...........................................................................................................................................

របួសដែលអាចមើលឃើញ សភាពផ្លូវអារម្មណ៍ ។ល។

...........................................................................................................................................

...........................................................................................................................................

...........................................................................................................................................

...........................................................................................................................................

...........................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

## វិធានការដែលបានធ្វើ

បុគ្គលដែលត្រូវបានជូនដំណឹង
នៅក្នុងតំណក់ទឹក
ឈ្មោះ៖
.........................................................................................មុខតំណែង......................................
ឈ្មោះ៖
.........................................................................................មុខតំណែង......................................

ជាមួយអាជ្ញាធរ
ប្រសិនបើមាន សូមរៀបរាប់ដោយលម្អិត៖

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

ផ្សេងៗ

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

| | |
|---|---|
| ឈ្មោះអ្នករាយការណ៍ | ឈ្មោះបុគ្គលដែលត្រូវបានជូនដំណឹងនៅក្នុងតំណក់ទឹក |
| ហត្ថលេខា | ហត្ថលេខា |
| កាលបរិច្ឆេទ៖ ......................./...................... | កាលបរិច្ឆេទ៖ ......................./...................... |

យើងមិនចាត់ទុកកុមារជាការទាក់ទាញផ្នែកទេសចរណ៍ឡើយ និងយើងមានអារម្មណ៍ថា វាគឺជាទំនួលខុសត្រូវរបស់យើងក្នុងការការពារ និងពង្រឹងសុវត្ថិភាព និងសុខុមាលភាពរបស់កុមារដែលចូលរួមក្នុងគម្រោងរបស់យើង។

តំណក់ទឹកកម្ពុជាមានគោលនយោបាយការពារកុមារដែលអ្នកមកធ្វើទស្សនកិច្ចត្រូវអាន ឯកភាព និងចុះហត្ថលេខាមុនពេលធ្វើទស្សនកិច្ច (អ្នកអាចរកវាបាននៅលើវែបសាយត៍របស់យើង)។

ការធ្វើទស្សនកិច្ចមានលក្ខខណ្ឌដូចខាងក្រោម៖

- អ្នកធ្វើទស្សនកិច្ចដែលមានបំណងមកធ្វើទស្សនកិច្ចគម្រោងរបស់យើងដំបូងត្រូវទំនាក់ទំនងបុគ្គលទទួលខុសត្រូវមួយរូប (នាយក អ្នកសម្របសម្រួល ឬទីប្រឹក្សាបច្ចេកទេស)។ ប្រសិនបើមានការឯកភាពហើយ បុគ្គលដែលទទួលខុសត្រូវនោះត្រូវ ជូនដំណឹងដល់បុគ្គលិកអំពីការធ្វើទស្សនកិច្ចនេះ។
- អ្នកធ្វើទស្សនកិច្ចត្រូវបានអនុញ្ញាតឲ្យធ្វើទស្សនកិច្ចគម្រោង <u>តែ</u>បន្ទាប់ពីមានការឯកភាពពីបុគ្គលទទួលខុសត្រូវប៉ុណ្ណោះ។
- គេត្រូវបញ្ជាក់អំពីឆន្ទៈនៃការធ្វើទស្សនកិច្ចនេះជាមួយបុគ្គលទទួលខុសត្រូវ។
- អ្នកធ្វើទស្សនកិច្ចទាំងអស់ត្រូវចុះឈ្មោះនៅកន្លែងទទួលភ្ញៀវ។
- ការថតរូបមិនត្រូវបានអនុញ្ញាតឡើយ លើកលែងតែស្ថិតនៅក្នុងលក្ខខណ្ឌជាក់លាក់ដែលមាននៅក្នុងគោលនយោបាយការពារកុមារ។
- អ្នកធ្វើទស្សនកិច្ចត្រូវបានរួមដំណើរដោយបុគ្គលិកនៅគ្រប់ពេលវេលាទាំងអស់ និងត្រូវគោរពតាមគោលនយោបាយការពារកុមារ។
- ការផ្តល់អ្វីមួយដល់កុមារដោយផ្ទាល់ គឺមិនត្រូវបានអនុញ្ញាតឡើយ ពីព្រោះ DT ចង់ប្រព្រឹត្តចំពោះកុមារទាំងអស់ដែលស្ថិតនៅក្នុងគម្រោងរបស់ខ្លួនស្មើៗគ្នា។
- ប្រសិនបើអ្នកធ្វើទស្សនកិច្ចចង់ផ្តល់ប្រាក់ DT នឹងអញ្ជើញពួកគេឲ្យជ្រើសរើសយកការឧបត្ថម្ភដល់គណនេយ្យរបស់យើង។
- ដោយសារតែ DT មានថវិកាដើម្បីធានាចំពោះតម្រូវការរបស់កុមារ រាល់ការឧបត្ថម្ភ ត្រូវពិភាក្សាជាមួយក្រុម DT ជាមុនសិន ដើម្បីកំណត់អំពីតម្រូវការទាំងនោះ។
- ដោយសារបុគ្គលិកត្រូវទទួលខុសត្រូវចំពោះការអមដំណើរអ្នកធ្វើទស្សនកិច្ច ដូច្នេះការធ្វើទស្សនកិច្ចមិនអាចលើសពីពីរម៉ោងសម្រាប់គម្រោងប៉ោយប៉ែត និងអ្នកលឿង និងមួយម៉ោងសម្រាប់គម្រោងភ្នំពេញ។

- អ្នកធ្វើទស្សនកិច្ចត្រូវគោរពទំនៀមទំលាប់របស់កម្ពុជា និងស្លៀកពាក់ឲ្យបានសមស្រប នៅក្នុងបរិបទរបស់កម្ពុជា មានន័យថា អ្នកធ្វើទស្សនកិច្ចត្រូវស្លៀកខោ ឬសំពត់ ដែលគ្របដណ្តប់លើជើងរបស់ពួកគេ យ៉ាងហោចណាស់ ត្រឹមជង្គង់ និងអាវគ្របដណ្តប់លើខ្លួនប្រាណផ្នែកខាងលើ និងយ៉ាងតិចណាស់ត្រឹមស្មា។
- ផ្តល់អាទិភាពដល់អ្នកធ្វើទស្សនកិច្ចមកពីអង្គការដែល DT មានទំនាក់ទំនងជាមួយ ឬព្យាយាមបង្កើតទំនាក់ទំនងជាមួយ។

**តំណក់ទឹកនឹងអនុវត្តវិធានការផ្លូវច្បាប់ (ឧទាហរណ៍ រាយការណ៍ដល់អាជ្ញាធរពាក់ព័ន្ធ) ប្រឆាំងនឹងអ្នកធ្វើទស្សនកិច្ច នៅពេលដែលកង្វល់អំពីការរំលោភបំពានលើកុមារកើតមានឡើង។**

| | |
|---|---|
| អ្នកធ្វើទស្សនកិច្ច | តំណាង DT |
| ហត្ថលេខា | ហត្ថលេខា |
| ............................................................ | ............................................................ |
| ឈ្មោះ ...................................................... | ឈ្មោះ ...................................................... |
| កាលបរិច្ឆេទ.............................................. | កាលបរិច្ឆេទ.............................................. |

**តំណក់ទឹក** គឺជាអង្គការកម្ពុជាមួយដែលធ្វើការងារជាមួយកុមារដែលងាយរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ តាមរយៈការអនុវត្តសកម្មភាពនៃការស្តារនីតិសម្បទា ការធ្វើសមាហរណកម្មឡើងវិញ និងការទប់ស្កាត់។

កុមារប្រហែល ៨០០ នាក់ បានទទួលផលប្រយោជន៍ជារៀងរាល់ថ្ងៃពីគម្រោងខុសៗគ្នារបស់យើងដែលមានទីតាំងនៅក្នុងក្រុងប៉ោយប៉ែត ភ្នំពេញ និងអ្នកលឿង។ ការងាររបស់យើងអាចប្រព្រឹត្តទៅបានដោយសារមានការគាំទ្រពីម្ចាស់ជំនួយអន្តរជាតិ។ DT ធ្វើការងារដោយស្ថិតនៅក្រោមកិច្ចព្រមព្រៀងផ្លូវការជាមួយក្រសួងពាក់ព័ន្ធនៅក្នុងប្រទេសកម្ពុជា។

DT ធ្វើការជាមួយក្រុមគោលដៅដ៏ស្មុគស្មាញនៃកុមារដែលងាយរងគ្រោះ និងកុមារដែលបាត់បង់បុព្វសិទ្ធិ រួមមានជាអាទិ៍ ជនរងគ្រោះដោយសារការជួញដូរ កុមារដែលធ្វើការងារ ឬរស់នៅតាមចញ្ចើមថ្នល់ កុមារពិការ និងជនរងគ្រោះដោយអំពើកេងប្រវ័ញ្ច ឬការរំលោភបំពាន។ ក្រុម DT មានការប្តេជ្ញាចិត្តខ្ពស់ចំពោះការគាំទ្រកុមារទាំងនេះក្នុងការអភិវឌ្ឍសមត្ថភាពរបស់ពួកគេ និងបង្កើនឱកាសរបស់ពួកគេ ដើម្បីទទួលបានសិទ្ធិ និងតម្រូវការជាមូលដ្ឋានរបស់ពួកគេ។

សម្រាប់បុគ្គលខាងក្រៅ ពួកគេអាចនឹងពិបាកយល់អំពីបរិបទដ៏ស្មុគស្មាញដែលយើងកំពុងតែធ្វើការជាមួយ។ ដោយសារយើងផ្តោតលើការការពារកុមារ និងការគោរពបទដ្ឋានអប្បបរមា យើងមានការមឹងម៉ាត់ជាពិសេសចំពោះអ្នកមកធ្វើទស្សនកិច្ចដែលមកពីខាងក្រៅ។ ដើម្បីទប់ស្កាត់អ្នកធ្វើទស្សនកិច្ច និងអ្នកសារព័ត៌មានកុំឲ្យមានផលប៉ះពាល់អវិជ្ជមានចំពោះការងាររបស់យើង យើងបានបង្កើតសេចក្តីណែនាំ និងវិធានដូចខាងក្រោម៖

**តំណក់ទឹកកម្ពុជាស្នើសុំឲ្យអ្នកធ្វើទស្សនកិច្ចគោរពតាមវិធានខាងក្រោម៖**

១. DT មានគោលនយោបាយការពារកុមារដែលអ្នកត្រូវអាន ឯកភាព និងចុះហត្ថលេខា។ អ្នកនឹងត្រូវអានរបាយការណ៍សកម្មភាពប្រចាំឆ្នាំដែលធ្វើឡើងនាពេលថ្មីៗបំផុត ដើម្បីមានការយល់ដឹងកាន់តែច្បាស់អំពីការងាររបស់យើង។

២. អ្នកតែងតែត្រូវនៅជាមួយបុគ្គលិករបស់យើងមួយរូប។

៣. មុនពេលធ្វើកិច្ចសម្ភាសន៍ជាមួយកុមារ អ្នកត្រូវធ្វើការពិភាក្សា និងទទួលការឯកភាពពីនាយក និង/ឬអ្នកសម្របសម្រួលចំពោះប្រធានបទ និងសំណួររបស់អ្នក។

៤. សំណួរដែលអ្នកចង់សាកសួរកុមារ ត្រូវមានការពិភាក្សាជាមួយបុគ្គលិកទំនាក់ទំនងជាមុនសិន ដើម្បីជៀសវាងការជ្រៀតជ្រែកនៅក្នុងដំណើរការសុខុមាលភាព និងស្តារនីតិសម្បទារបស់កុមារ។

៥. នាយកប្រតិបត្តិទទួលខុសត្រូវស្វែងរកព័ត៌មានខាងក្រោម៖
- តើអ្នកណាជានិយោជករបស់អ្នក?
- តើប្រធានបទនៃការរាយការណ៍របស់អ្នកគឺជាអ្វី?
- តើវានឹងត្រូវបានគេចុះផ្សាយនៅកន្លែងណា?
- តើអ្នកមានគម្រោងស្នាក់នៅរយៈពេលប៉ុណ្ណា?
- តើក្រុមរបស់អ្នកមានសមាជិកប៉ុន្មាននាក់?
- ហេតុអ្វីបានជាអ្នកជ្រើសរើសតំណក់ទឹកសម្រាប់របាយការណ៍នេះ?
- សំណួរដទៃទៀតដែលមិនបានលើកឡើងនៅទីនេះ ប៉ុន្តែត្រូវបានចាត់ទុកថា មានការពាក់ព័ន្ធនៅក្នុងស្ថានភាពជាក់លាក់។

៦. អ្នកត្រូវគោរពសេចក្តីថ្លៃថ្នូរ ភាពឯកជន និងភាពស្និទ្ធស្នាលរបស់កុមារ។
បុរសមិនអាចចូលក្នុងផ្ទះដែលស្ត្រីស្នាក់នៅបានឡើយ។
ស្ត្រីមិនអាចចូលក្នុងផ្ទះដែលបុរសស្នាក់នៅបានឡើយ។

៧. រាល់អ្នកធ្វើទស្សនកិច្ចគួរតែមានការយល់ដឹងអំពីការដាក់កំហិតលើការថតរូប និងខ្សែវីដេអូរបស់ DT។
- មិនត្រូវថតរូបដោយគ្មានការអនុញ្ញាតពីបុគ្គលិក និងការយល់ព្រមរបស់កុមារ។
- មិនអាចថតរូប ឬខ្សែវីដេអូដោយគ្មានវត្តមានរបស់បុគ្គលិក។
- យោតាមច្បាប់ស្តីពីការជួញដូរ សារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយដទៃទៀតត្រូវបានហាមឃាត់មិនឲ្យបោះពុម្ពផ្សាយ ឬផ្សព្វផ្សាយណាមួយ ដែលអាចនាំឲ្យសាធារណជនដឹងអំពីអត្តសញ្ញាណរបស់ជនរងគ្រោះនៅក្នុងបទល្មើសដែលមានចែងនៅក្នុងច្បាប់នេះ។
- គេមិនអាចលើកឡើងអំពីឈ្មោះពេញរបស់កុមារនៅក្នុងការបោះពុម្ពផ្សាយ ឬផ្សព្វផ្សាយណាមួយឡើយ។
- ការថតរូបកុមារអាក្រាតកាយ ឬពាក់កណ្តាលអាក្រាតត្រូវបានហាមឃាត់ដាច់ខាត។

សំណើបន្ថែមទៀត៖

- អត្ថបទ ឬសម្ភារដែលផលិតដោយប្រើគម្រោងរបស់ DT ជាប្រធានបទ ត្រូវឆ្លុះបញ្ចាំងអំពីទស្សនវិស័យ និងបេសកកម្មរបស់អង្គការ ក៏ដូចជានៅក្នុងការបកប្រែផងដែរ។
- មុនពេលបោះពុម្ពផ្សាយអត្ថបទ ឬឯកសារ ។ល។ ណាមួយ យើងរំពឹងទុកថា អ្នកនឹងបង្ហាញយើងអំពីសំណៅចុងក្រោយ ហើយ DT មានសិទ្ធិស្នើសុំការកែប្រែ។
- អាសយដ្ឋានរបស់ DT នឹងត្រូវបង្ហាញយ៉ាងច្បាស់នៅក្នុងអត្ថបទ ឬឯកសារចុងក្រោយ ។ល។
- សំណៅគំរូនឹងត្រូវផ្ញើទៅកាន់ការិយាល័យរបស់យើងនៅពេលបោះពុម្ពផ្សាយ។
- សំណៅចម្លងរូបថត និងវីដេអូច្បាប់ដើមគួរតែចែករំលែកជាមួយ DT។

**កង្វះខាតការគោរពចំពោះវិធានការទាំងនោះអាចនាំឲ្យមានការអនុវត្តនីតិវិធីតាមផ្លូវច្បាប់។**

**ដំណាក់ទឹកនឹងអនុវត្តវិធានការតាមផ្លូវច្បាប់ (ឧទាហរណ៍ រាយការណ៍ជូនអាជ្ញាធរពាក់ព័ន្ធ) ប្រឆាំងនឹងអ្នកសារព៌មាននៅពេលកង្វល់អំពីការរំលោភបំពានលើកុមារបានកើតឡើង។**

| **ឈ្មោះអ្នកសារព័ត៌មាន**<br>**ឈ្មោះប្រព័ន្ធផ្សព្វផ្សាយដែលត្រូវបានតំណាង** | **តំណាងរបស់តំណាក់ទឹក** |
|---|---|
| កាលបរិច្ឆេទ ......................../......................<br>ហត្ថលេខា | កាលបរិច្ឆេទ......................../......................<br>ហត្ថលេខា |

តំណក់ទឹក គឺជាអង្គការកម្ពុជាមួយដែលធ្វើការងារជាមួយកុមារដែលងាយរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ តាមរយៈការអនុវត្តសកម្មភាពនៃការស្តារនីតិសម្បទា ការធ្វើសមាហរណកម្មឡើងវិញ និងការទប់ស្កាត់។
កុមារប្រហែល ៨០០ នាក់ បានទទួលផលប្រយោជន៍ជារៀងរាល់ថ្ងៃពីគម្រោងខុសៗគ្នារបស់យើងដែលមានទីតាំងនៅក្នុងក្រុងប៉ោយប៉ែត ភ្នំពេញ និងអ្នកលឿង។ ការងាររបស់យើងអាចប្រព្រឹត្តទៅបានដោយសារមានការគាំទ្រពីម្ចាស់ជំនួយអន្តរជាតិ។ DT ធ្វើការងារដោយស្ថិតនៅក្រោមកិច្ចព្រមព្រៀងផ្លូវការជាមួយក្រសួងពាក់ព័ន្ធនៅក្នុងប្រទេសកម្ពុជា។

DT ធ្វើការជាមួយក្រុមគោលដៅដ៏ស្មុគស្មាញនៃកុមារដែលងាយរងគ្រោះ និងកុមារដែលបាត់បង់បុព្វសិទ្ធិ រួមមានជាអាទិ៍ ជនរងគ្រោះដោយសារការជួញដូរ កុមារដែលធ្វើការងារ ឬរស់នៅតាមចញ្ចើមថ្នល់ កុមារពិការ និងជនរងគ្រោះដោយអំពើកេងប្រវ័ញ្ច ឬការរំលោភបំពាន។ ក្រុម DT មានការប្តេជ្ញាចិត្តខ្ពស់ចំពោះការគាំទ្រកុមារទាំងនេះក្នុងការអភិវឌ្ឍសមត្ថភាពរបស់ពួកគេ និងបង្កើនឱកាសរបស់ពួកគេ ដើម្បីទទួលបានសិទ្ធិ និងតម្រូវការជាមូលដ្ឋានរបស់ពួកគេ។

DT ផ្តោតការយកចិត្តទុកដាក់ជាពិសេសចំពោះបុគ្គលដែលមានទំនាក់ទំនងជាមួយអ្នកទទួលផល រួមមាន អ្នកធ្វើទស្សនកិច្ច អ្នកសារព័ត៌មាន បុគ្គលិកក្នុងស្រុក និងបុគ្គលិកអន្តរជាតិ។ **ដូច្នេះ DT មានគោលនយោបាយការពារកុមារមួយដែលបុគ្គលគ្រប់រូបដែលពាក់ព័ន្ធនៅក្នុង DT គួរតែអាន ចុះហត្ថលេខា និងអនុវត្តតាម។**

ចំនួនដ៏ច្រើននៃពាក្យសុំរបស់អ្នកស្ម័គ្រ ដែល DT ទទួលបាន បានធ្វើឲ្យយើងអនុវត្តគោលនយោបាយបន្ថែមមួយទៀតដែលបេក្ខជនស្ម័គ្រចិត្តត្រូវអនុវត្តតាម។ បុគ្គលដែលមានបំណងធ្វើជាអ្នកស្ម័គ្ររបស់ DT ត្រូវបានគេរំពឹងទុកថា៖

១. ធ្វើការងារផ្អែកតាមតម្រូវការរបស់អង្គការ
២. ធ្វើការដើម្បីកសាងសមត្ថភាពរបស់បុគ្គលិកក្នុងស្រុកដើម្បីបង្កើននិរន្តរភាពរបស់អង្គការ។

ដូច្នេះ

៣. DT នឹងមិនធ្វើការងារជាមួយអ្នកស្ម័គ្រចិត្តលើមុខតំណែងដែលបុគ្គលិកក្នុងស្រុកអាចធ្វើបានឡើយ (ដូចជាការបង្រៀន)។
៤. មិនអនុញ្ញាតឲ្យមានអន្តរកម្មដោយផ្ទាល់ជាមួយកុមារ ដោយគ្មានការចូលរួមពីបុគ្គលិកក្នុងស្រុកឡើយ។

ក្រៅពីលក្ខខណ្ឌខាងលើ បុគ្គលដែលមានបំណងធ្វើការងារស្ម័គ្រចិត្តនៅ DT ត្រូវអនុវត្តតាមលក្ខខណ្ឌខាងក្រោម៖

- អាចធ្វើការក្នុងរយៈពេលវែងបាន យ៉ាងតិចបីខែ (លើកលែងវេជ្ជបណ្ឌិត)
- មានអាយុអប្បបរមា ២៣ ឆ្នាំ
- បញ្ចប់ការសិក្សាជំនាញដែលចាំបាច់
- មានបទពិសោធន៍ធ្វើការលើជំនាញដែលចាំបាច់
- មានបទពិសោធន៍ការងារក្រៅប្រទេស មានអាទិភាពចំពោះការធ្វើការងារក្នុងប្រទេសកំពុងអភិវឌ្ឍន៍
- ផ្តល់ដល់ DT នូវភ័ស្តុតាង ឬលិខិតបញ្ជាក់ជាផ្លូវការអំពីកិរិយាមាយាទ
- មានសុខភាពល្អ
- ប្រាកដថា បានចាក់ថ្នាំបង្ការដែលចាំបាច់ទាំងអស់
- រៀបចំទីកន្លែងស្នាក់នៅដោយខ្លួនឯងផ្ទាល់ (មិនអនុញ្ញាតឲ្យស្នាក់នៅក្នុងមណ្ឌលឡើយ)

បុគ្គលដែលមានចំណាប់អារម្មណ៍ចំពោះការធ្វើការងារស្ម័គ្រចិត្តនៅ DT គួរតែផ្ញើលិខិតចំណាប់អារម្មណ៍ ប្រវត្តិរូបសង្ខេប ឯកសារយោង និងភ័ស្តុតាង/លិខិតបញ្ជាក់កិរិយាមាយាទជាផ្លូវការមកកាន់អង្គការតំណក់ទឹកដោយដាក់ជូនការិយាល័យរបស់នាយកប្រតិបត្តិ៖ ed@damnoktoek.org